# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១១៥២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល នៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១២៩៧ / ៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០១០៨ / ០៣៩ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិទី ២ នៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលមានសមាសភាពដូចខាងក្រោម ÷

១- ឯកឧត្តម **ម៉ូល តីឌូ** តំណាងមន្ត្រីរាជការស៊ីវិល ជំនួសលោក អ៊ុក សំបូរ សមាជិក

២- ឯកឧត្តម **សរ សុពុត្រា** តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជំនួសលោក ហ៊ល ផល សមាជិក

៣- លោក **ឌិត សារឿន** តំណាងក្រសួងយុត្តិធម៌ ជំនួសលោក ស៊ឹម ឫទ្ធីសែន សមាជិក

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងសមាសភាពដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី 09 ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
ដូចមាត្រា ៣
រាជកិច្ច
ឯកសារ - កាលប្បវត្តិ